# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ លោកអាភីស៊ិត អតីតនាយករដ្ឋមន្ត្រីថៃ ត្រូវទទួលបាបកម្មហើយ ដោយអំពើឈ្លានពានខ្មែរ ។

www.hoksavann.org

ថ្ងៃទី១២ កក្កដា ២០១១



លោកអាភីស៊ិតបានទទួលធ្វើជានាយករដ្ឋមន្ត្រី បន្ទាប់ពីអំពើរដ្ឋប្រហារនៃកងទ័ពថៃទម្លាក់លោកថាក់ស៊ីន-ស៊ីណាវ៉ាត្រា ជានាយករដ្ឋមន្ត្រីស្របច្បាប់ ។ បន្ទាប់ពីបានទទួលតំណែងមក លោកអាភីស៊ិតបានរករឿងជាមួយខ្មែរជាប់ជានិច្ច ។ គាត់នេះបានទាមទារដីនៅជុំវិញប្រាសាទព្រះវិហារទំហំ៤.៦គីឡូម៉ែត្រក្រឡា ដោយធ្វើផែនទីក្លែងក្លាយគូរខ្លួនឯងជាឯកតោភាគី។ មិនតែប៉ុណ្ណោះ បានបញ្ជាឲ្យទាហានថៃវាយប្រហារមកលើទឹកដីកម្ពុជា ដោយផ្លោងគ្រាប់បែកជាច្រើនម៉ឺនគ្រាប់ ជាគ្រាប់បែកធុនធ្ងន់ រហូតដល់មានការប្រើគ្រាប់បែកចង្កោមដែលពិភពលោកហាមថែមទៀត ។ អំពើវាយប្រហារនេះ បានធ្វើឲ្យទាហាននិងពលរដ្ឋខ្មែរត្រូវរបួសនិងស្លាប់អស់ជាច្រើន។ មិនតែប៉ុណ្ណោះពលរដ្ឋខ្មែររាប់ម៉ឺននាក់បានត្រូវភៀសខ្លួនពីកន្លែងកើតហេតុទៅរកកន្លែងសុវត្ថិភាព ។ លើសពីនេះទៀត ការវាយប្រហារនេះបានធ្វើឲ្យប្រាសាទព្រះវិហារខូចខាតជាច្រើនកន្លែង ។

អំពើឧក្រិដ្ឋកម្មរបស់អាភីស៊ិត បានបាញ់ផ្លោងចូលក្នុងវត្តកែវសិក្ខាគិរីស្វារៈ បានធ្វើឲ្យខូចខាតអគារពុទ្ធសាសនា ជាពិសេសព្រះពុទ្ធរូបបានត្រូវបាក់បែក ។ តាមច្បាប់ព្រះពុទ្ធសាសនា ការបំផ្លាញបូជនីយដ្ឋាននិងបូជនីយវត្ថុរបស់ព្រះពុទ្ធសាសនាមានទោសយ៉ាងធ្ងន់ ហើយទោសនោះនឹងត្រូវទទួលក្នុងបច្ចុប្បន្នជាតិនេះ ។ ទោះបីគេសង្កេតឃើញថា ទាហានថៃហាក់ដូចជាស្ថិតនៅក្រោមអំណាចព្រះមហាក្សត្រថៃក៏ដោយ ប៉ុន្តែតាំងពីតុលាការក្រុងឡាអេ ដែលបានកាត់សេចក្តីឲ្យខ្មែរឈ្នះក្តីព្រះវិហារឆ្នាំ១៩៦២មក រាជរដ្ឋាភិបាលថៃជាច្រើនជំនាន់ មិនបានវាយប្រហារខ្មែរ ដូចសម័យអាភីស៊ិតនេះឡើយ ។ លោកអាភីស៊ិតបានប្រឆាំងនឹងក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ដោយពុំព្រមអនុវត្តតាមសមាគមនៃប្រជាជាតិអាស៊ីភាគអាគ្នេយ៍ដែលអង្គការនេះប្រគល់ឲ្យ ដើម្បីបញ្ចប់ការប្រយុទ្ធគ្នារវាងខ្មែរនិងថៃ ។ អាភីស៊ិតពុំព្រមឲ្យឥណ្ឌូណេស៊ី ដែលជាតំណាងសមាគមអាស៊ានពិនិត្យមើលការឈប់បាញ់គ្នាឡើយ ។ ជនកំណាចនេះចេះតែនិយាយដដែលៗថា បញ្ហាខ្មែរត្រូវដោះស្រាយជាទ្វេភាគីរវាងខ្មែរនិងថៃ មិនត្រូវមានអ្នកទីបីឡើយ ។ មួយផ្នែកទៀត អាភីស៊ិតបានរាំងគណៈកម្មាធិការបេតិកភ័ណ្ឌពិភពលោក ដែលប្រជុំគ្នានៅប្រទេសបារាំង កុំឲ្យយកសំណើរបស់ខ្មែរយកទៅពិនិត្យ ដែលស្នើឲ្យអភិវឌ្ឍន៍ជុំវិញប្រាសាទព្រះវិហារ និងជួសជុលប្រាសាទនេះឡើងវិញ បន្ទាប់ពីថៃបានផ្លោងគ្រាប់បែកបំផ្លាញ ។

ឥឡូវនេះ អំពើបិទបាំងរបស់ជនពាលអាភីស៊ិត បានត្រូវពិភពលោកបានដឹងការពិតហើយ តាមរយៈគណៈកម្មាធិការបេតិកភ័ណ្ឌពិភពលោកបានច្រានចោលសំណើរបស់ថៃ ដែលរារាំងកុំឲ្យយកសំណើរបស់ខ្មែរទៅពិនិត្យ ។ គណៈប្រតិភូរបស់អាភីស៊ិតបានដើរចេញពីអង្គប្រជុំយ៉ាងអាម៉ាស់ ព្រមទាំងលាឈប់ពីគណៈកម្មាធិការនេះផង ។ បរាជ័យរបស់អាភីស៊ិតមិនត្រឹមតែប៉ុណ្ណឹងទេ អាភីស៊ិតបានត្រូវពលរដ្ឋថៃរបស់ខ្លួនដេញចេញពីតំណែង តាមរយៈការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ គឺគណបក្សប្រជាធិបតេយ្យរបស់អាភីស៊ិតបានចាញ់ឆ្នោតគណបក្សភឿថៃរបស់អ្នកស្រីយីងឡាក់ ជាប្អូនស្រីរបស់លោកថាក់ស៊ីន ដែលត្រូវគេធ្វើរដ្ឋប្រហារទម្លាក់លោកពីតំណែង ។ គណបក្សភឿថៃបានឈ្នះតំណាងរាស្ត្រច្រើន អាចបង្កើតរដ្ឋាភិបាលបាន ហើយអ្នកស្រីយីងឡាក់អាចក្លាយជានាយករដ្ឋមន្ត្រី បើគ្មានបញ្ហានយោបាយជ្រៀតជ្រែកទេ ។ អាភីស៊ិតជានាយករដ្ឋមន្ត្រីចាំផ្ទះបានទទួលស្គាល់បរាជ័យគណបក្សប្រជាធិបតេយ្យរបស់ខ្លួន ក៏សុំលាលែងពីប្រធានបក្ស ។ តើវាសនារបស់អាភីស៊ិតនឹងទៅជាយ៉ាងណា បើតាមកំហុសដែលវាមើលងាយខ្មែរ និងកំហុសដែលសម្លាប់ពួកអាវក្រហមជិត១០០នាក់ សមគួរឡើងតុលាការកាត់ទោស ។ ប៉ុន្តែបើវាសនារបស់វានៅមានមិនទាន់ទទួលបាបកម្មនេះ ជាពិសេសបាបកម្មដែលវាឲ្យទាហានថៃបាញ់ផ្លោងបំផ្លាញវត្តខ្មែរកែវសិក្ខាគិរីស្វារៈ ធ្វើឲ្យព្រះពុទ្ធរូបជាទីសក្ការៈត្រូវបាក់បែក វាអាចឡើងកាន់តំណែងនាយករដ្ឋមន្ត្រីជាថ្មីតាមរយៈរដ្ឋប្រហារ របស់ពួកអាមាត្យដែលមានព្រះមហាក្សត្រថៃនៅពីក្រោយ ។ ប៉ុន្តែបាបកម្មដែលជននេះបានសាងមកលើប្រទេសកម្ពុជា ជាពិសេសបាញ់បំផ្លាញវត្តព្រះពុទ្ធសាសនាខ្មែរ ជននេះនឹងត្រូវទទួលទោសទណ្ឌកម្មក្នុងពេលណាមួយពុំខានឡើយ ។ ការទទួលដំណឹងថា អាភីស៊ិតត្រូវអស់អំណាច ធ្វើឲ្យអ្នកដឹកនាំនិងពលរដ្ឋខ្មែរបានធូរទ្រូងបន្តិចដែរ ដោយសង្ឃឹមថា អ្នកដឹកនាំថៃក្រោយនឹងធ្វើឲ្យទំនាក់ទំនងរវាងខ្មែរនិងថៃមានភាពល្អ និងដំណោះស្រាយជម្លោះនឹងប្រព្រឹត្តទៅដោយសន្តិវិធី ។

សូមជនជាតិខ្មែរគ្រប់ឋានៈគប្បីចងចាំថា ទោះបីនយោបាយថៃប្រព្រឹត្តទៅយ៉ាងណាក៏ដោយ ខ្មែរត្រូវតែប្រុងប្រយ័ត្នជានិច្ច ព្រោះថៃត្រូវនឹងយើងក្តី សត្រូវនឹងយើងក្តី ជាថៃតែមួយ គំនិតជាតិនិយមគេខ្ពស់ណាស់ គេឈ្លោះគ្នាគេ ថៃម្ខាងពុំដែលពឹងបរទេសឲ្យជួយកំចាត់គ្នាគេឡើយ ជាពិសេសជនជាតិជាចោរនេះ ចេះតែពង្រីកទឹកដី ទាំងដីគោកទាំងសមុទ្រមកលើប្រទេសជិតខាង ជាពិសេសមកលើប្រទេសកម្ពុជា ។ គោលសំខាន់ ខ្មែរត្រូវតែរួបរួមគ្នាឲ្យមានឯកភាពជាតិ ក្នុងដំណោះស្រាយបញ្ហាជាតិ កុំឲ្យសត្រូវយកទឹកដីខ្មែរទៀតបាន ។៚

*　　*

*